ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំពិធីបុណ្យព្រះសព សម្តេចព្រះធម្មលិខិត លាស់ ឡាយ សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា ប្រធានថេរសភាព្រះពុទ្ធសាសនា និងជា ព្រះចៅអធិការវត្តសន្សំកុសល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹតលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ ៖** ត្រូវបានបង្កើតគណៈកម្មការរៀបចំពិធីបុណ្យថ្វាយព្រះសពសម្តេចព្រះធម្មលិខិត **លាស់ ឡាយ** សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា ប្រធានថេរសភាព្រះពុទ្ធសាសនា និងជាព្រះចៅអធិការវត្តសន្សំកុសល ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** | ព្រះប្រធានកិត្តិយស |
| ២-សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** | ព្រះប្រធានកិត្តិយស |
| ៣-សម្តេចព្រះពោធិវ័ង្ស **អ៊ំ លឹមហេង** | ព្រះអនុប្រធាន |
| ៤-សម្តេចព្រះវនរ័ត **ណយ ច្រឹក** | ព្រះអនុប្រធាន |

| | |
|---|---|
| ៥-សម្តេចព្រះពុទ្ធជ័យមុនី ឃឹម សន | ព្រះអនុប្រធាន |
| ៦-ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន | ប្រធាន |
| ៧-ឯកឧត្តម ហ៊ឹម ឆែម | អនុប្រធាន |
| ៨-អ្នកឧកញ៉ាភក្តីព្រះស្តេច ហេង តឹមគុណ | អនុប្រធាន |
| ៩-ឯកឧត្តម ឈិន កេតនា | អនុប្រធានអចិន្ត្រៃយ៍ |
| ១០-ឯកឧត្តមបណ្ឌិត ប៉ែន ស៊ីម៉ន | សមាជិក |
| ១១-ឯកឧត្តម វង្សី វិស្សុត | សមាជិក |
| ១២-ឯកឧត្តម សេង ទៀង | សមាជិក |
| ១៣-ឯកឧត្តមនាយឧត្តមសេនីយ៍ ហ៊ីង ប៊ុនហៀង | សមាជិក |
| ១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ សៅ សុខា | សមាជិក |
| ១៥-ឯកឧត្តម បួន លីមហេង | សមាជិក |
| ១៦-ឯកឧត្តម ញ៉ែម វ៉ាលី | សមាជិក |
| ១៧-ឯកឧត្តម សេង សុមុនី | សមាជិក |
| ១៨-ឯកឧត្តម សាក៉យ ឆុន | សមាជិក |
| ១៩-ឯកឧត្តម ឃួង ស្រេង | សមាជិក |
| ២០-ឯកឧត្តមនាយឧត្តមសេនីយ៍ ឥត សារ៉ាត់ | សមាជិក |
| ២១-ឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត | សមាជិក |
| ២២-គណៈកម្មការ-អាចារ្យ វត្តសន្សំកុសល | សមាជិក |

**ប្រការ២៖** គណៈកម្មការនេះមានភារកិច្ចដូចតទៅ៖

- រួមសហការជាមួយក្រសួង-ស្ថាប័ននានា និងគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំព្រះរាជពិធីបុណ្យព្រះសព តាមប្រពៃណីជាតិ ប្រព្រឹត្តទៅឲ្យបានល្អប្រសើរ
- ពិនិត្យ និងលើកសំណើរដោះស្រាយរាល់ការលំបាកនានា និងរៀបចំពិធីបុណ្យ និងពិធីតម្កល់ព្រះសពដែលតម្កល់ក្នុងវត្តសន្សំកុសល ។
- ទទួលបន្ទុករៀបចំក្បួនដង្ហែព្រះសព តុបតែងរថយន្តបុស្បុក និងការធ្វើព្រះមេរុបូជាព្រះសព សម្តេចព្រះធម្មលិខិត លាស់ ឡាយ ឱ្យបានសក្តិសមទៅនឹងព្រះកិត្តិយសព្រះសព។
- រៀបចំឱ្យមានកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងពិធីបុណ្យព្រះសព និងពេលដង្ហែព្រះសពឱ្យបានល្អប្រសើរ។
- រៀបចំកម្មវិធីបុណ្យ អញ្ជើញថ្នាក់ដឹកនាំចូលរួមដង្ហែនិងបូជាព្រះសព ធ្វើប្លង់ដង្ហែព្រះសព ។ល។
- រៀបចំទទួលបដិសណ្ឋារកិច្ចថ្នាក់ដឹកនាំ និងភ្ញៀវដែលបានអញ្ជើញចូលរួមក្នុងពិធីបុណ្យព្រះសព និងគោរពព្រះវិញ្ញាណក្ខន្ធព្រះសព។
- រៀបចំវេទិកាសម្រាប់ភ្ញៀវកិត្តិយស វេទិកាព្រះសង្ឃ និងពុទ្ធបរិស័ទ កៅអី តុ ទេយ្យទាន ភេសជ្ជៈ និងផ្កាខ្លឹមចន្ទន៍។

- លើកគំរោង និងគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋ និងសប្បុរសជនក្នុងការបម្រើឱ្យពិធីបុណ្យព្រះសព បានប្រព្រឹត្តទៅល្អប្រសើរ។
- បំពេញភារកិច្ចជាក់ស្តែងផ្សេងៗទៀតតាមការចាំបាច់សម្រាប់បម្រើឱ្យពិធីបុណ្យព្រះសព។

**ប្រការ៣៖** គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការនិងក្រុមការងារបន្ថែមជាជំនួយការ និងប្រើប្រាស់មន្ត្រីក្រោមឱវាទតាមការចាំបាច់ដើម្បីធានាឱ្យការរៀបចំបុណ្យព្រះសពប្រព្រឹត្តទៅតាមប្រពៃណីបានល្អប្រសើរ។ គណៈកម្មការនេះប្រើប្រាស់ត្រាទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីដំណើរការការងាររបស់ខ្លួន។

**ប្រការ៤៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ២កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :
- -គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- -ក្រសួងការពារជាតិ
- -ក្រសួងមហាផ្ទៃ
- -ក្រសួងធម្មការ និងសាសនា
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- -រដ្ឋបាលរាជធានីភ្នំពេញ
- -រាជកិច្ច
- -ដូចប្រការ៤ "ដើម្បីអនុវត្ត"
- -ឯកសារកាលប្បវត្តិ